# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីសម្រេចបន្តអាណត្តិ

## អាជ្ញាប័ណ្ណរួមលេខ ០៤៥ ឯអ

## ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៣ សម្រាប់លោក កែវ ដារ៉ា

# អាជ្ញាធរអគ្គិសនីកម្ពុជា

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយពៈរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-យោងឯកសារអាជ្ញាប័ណ្ណលេខ០៤៥ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឱ្យលោក កែវ ដារ៉ា នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៣

-យោងពាក្យស្នើសុំបន្តអាណត្តិអាជ្ញាប័ណ្ណរបស់លោក កែវ ដារ៉ា ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៥

-យោងកំណត់បង្ហាញសុំបន្តអាណត្តិអាជ្ញាប័ណ្ណរបស់លេខាធិការដ្ឋានលេខ ០២៤-០៥-លជ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ ២០០៥

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៥ ដល់ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៥

-យោងតាមការអនុម័តរបស់សម័យប្រជុំរបស់ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី៥៤ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៥

## សម្រេច

**ប្រការ១**

ដោយលោក **កែវ ដារ៉ា** បានកែលំអមធ្យោបាយធ្វើសេវាកម្មអគ្គិសនីរបស់ ខ្លួនបានមួយចំនួន ហើយត្រូវធ្វើការកែលំអច្រើនបន្ថែមទៀតនៅឆ្នាំបន្តបន្ទាប់ ដើម្បីឱ្យស្របតាមល័ក្ខខ័ណ្ឌទូទៅនៃស្តង់ដាបច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចកែសម្រួលអាជ្ញាប័ណ្ណរួមលេខ ០៤៥ ឯអ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៣ ដែលបានផ្តល់ជូនលោក **កែវ ដារ៉ា** ដោយបន្តអាណត្តិអាជ្ញាប័ណ្ណសាកល្បងចុងក្រោយចំនួន ២ឆ្នាំ ទៀត ។

**ប្រការ២**

អាណត្តិថ្មីរបស់អាជ្ញាប័ណ្ណនេះ មានរយៈពេល ២ឆ្នាំ គិតចាប់ពីថ្ងៃទី១៨ ខែ សីហា ឆ្នាំ២០០៥ និងអាចស្នើសុំបន្តទៀត ឬស្នើសុំកែសម្រួលលើកលែងតែត្រូវដកហូត ដោយអនុលោមតាមល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ។

**ប្រការ៣**

សេចក្តីសម្រេចនេះ ត្រូវក្លាយជាផ្នែកមួយនៃអាជ្ញាប័ណ្ណលេខ ០៤៥ ឯអ ។

**ប្រការ៤**

ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ០៤៥ ឯអ ត្រូវ ស្ថិតនៅជាធរមានដដែល ។

**ប្រការ៥**

សេចក្តីសម្រេចនេះ ត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៦**

អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្ញើសេចក្តីសម្រេចនេះទៅតម្កល់ទុកបន្ថែមនៅតាមទី កន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ០៤៥ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណលេខ ០៤៥ឯអ ដែលតម្កល់មានការកែសំរួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។

ភ្នំពេញ, ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៥

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

# ឧបសម្ព័ន្ធទី២
# មធ្យោបាយផលិតកម្មដែលមានស្រាប់របស់អ្នកកាន់អាជ្ញាប័ណ្ណ

## ក_មធ្យោបាយផលិតកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ

**រោងម៉ាស៊ីន**

១- ទីតាំងម៉ាស៊ីនរបស់អ្នកកាន់អាជ្ញាប័ណ្ណ ស្ថិតក្នុងភូមិកំពង់ពពិល ឃុំ កំពង់ពពិល ស្រុកពារាំង ខេត្តព្រៃវែង ។

**លក្ខណៈទូទៅនៃម៉ាស៊ីន**

១- អ្នកកាន់អាជ្ញាប័ណ្ណ មានម៉ាស៊ីនភ្លើងចំនួន ០៣គ្រឿង ដែលមានអានុភាព តំឡើងសរុប 85 kVA គឺ:

-ម៉ាស៊ីនលេខ១ អានុភាព 25 kVA

-ម៉ាស៊ីនលេខ២ អានុភាព 35 kVA

-ម៉ាស៊ីនលេខ៣ អានុភាព 25 kVA

២- ម៉ាស៊ីនភ្លើងខាងលើ ប្រើប្រាស់ប្រេងម៉ាស៊ូតដៀសែល ។

លក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណនេះមានខ្លឹមសារដូចអាជ្ញាប័ណ្ណលេខ០១៥.ឯអ ចុះថ្ងៃទី២២ ខែវិច្ឆិការ ឆ្នាំ២០០២។ ប្រសិនបើចង់ពិនិត្យមើលខ្លឹមសារ សូមពិនិត្យមើលផ្នែកទី២ របស់អាជ្ញាប័ណ្ណនេះ ។